ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :............០៤៤/២១............ក.ប/ ស.ស.រ.ង.ល

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ដើម្បីអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការបិទខ្ទប់ ភូមិសាស្ត្រនានា ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញ-ចូល
- បានឃើញអនុក្រឹត្យ២៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាលដើម្បី ទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញ-ចូល
- សេចក្តីសម្រេចលេខ៥៤សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈកម្មការ ដើម្បីអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការបិទខ្ទប់ភូមិសាស្ត្រនានា ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **អ៊ិត សំហេង** | រដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម | **ពេជ សោភ័ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ហេង សួរ** | រដ្ឋលេខាធិការ | អនុប្រធានប្រចាំការ |
| ៤. | ឯកឧត្តម | **ហុង ជឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥. | លោកជំទាវ | **សុវណ្ណ វណ្ណារតន៍** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦. | ឯកឧត្តម | **អ៊ុក សមវិទ្យា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម | អនុប្រធាន |
| ៧. | ឯកឧត្តម | **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ | សមាជិក |
| ៨. | ឯកឧត្តម | **ម៉ន ត្រីយ៉ា** | រដ្ឋលេខាធិការ | សមាជិក |
| ៩. | ឯកឧត្តម | **ប្រាក់ ចាន់ធឿន** | រដ្ឋលេខាធិការ | សមាជិក |
| ១០. | ឯកឧត្តម | **ម៉ុង គឹមហេង** | រដ្ឋលេខាធិការ | សមាជិក |
| ១១. | ឯកឧត្តម | **ប៉ុក ប៉ាន់** | រដ្ឋលេខាធិការ | សមាជិក |
| ១២. | ឯកឧត្តម | **ឡេង សែ** | រដ្ឋលេខាធិការ | សមាជិក |
| ១៣. | លោកជំទាវ | **សៅ ស្រីពៅ** | រដ្ឋលេខាធិការ | សមាជិកា |
| ១៤. | ឯកឧត្តម | **ចាប ឫទ្ធី** | រដ្ឋលេខាធិការ | សមាជិក |
| ១៥. | ឯកឧត្តម | **ផេង សុខាំ** | រដ្ឋលេខាធិការ | សមាជិក |
| ១៦. | ឯកឧត្តម | **គុយ រតនា** | រដ្ឋលេខាធិការ | សមាជិក |
| ១៧. | ឯកឧត្តម | **ឡៅ ហ៊ីម** | រដ្ឋលេខាធិការ | សមាជិក |
| ១៨. | ឯកឧត្តម | **ជួន មុំថុល** | រដ្ឋលេខាធិការ | សមាជិក |
| ១៩. | ឯកឧត្តម | **សោម អូន** | រដ្ឋលេខាធិការ | សមាជិក |
| ២០. | ឯកឧត្តម | **ឱុយ ស៊ីផាន់** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២១. | លោកជំទាវ | **សួស រដ្ឋាទី** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ២២. | ឯកឧត្តម | **ឱុយ រិទ្ធ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៣. | ឯកឧត្តម | **ឡៀង ម៉ាក់គែល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៤. | ឯកឧត្តម | **អ៊ិន ខេមរា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៥. | ឯកឧត្តម | **គុយ ទេពដារាឧត្ដម** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៦. | ឯកឧត្តម | **លី សុធា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៧. | ឯកឧត្តម | **ទេព ណារ៉ាទី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៨. | ឯកឧត្តម | **សោម ចំណាន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៩. | លោកជំទាវ | **ជា សុខនី** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ៣០. | ឯកឧត្តម | **ប៉ាន់ ណារ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៣១. | ឯកឧត្តម | **អ៊ុក ដារ៉ា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៣២. | ឯកឧត្តម | **ខឿ សំអាង** | អនុរដ្ឋលេខាធិការ | សមាជិក |

| | | | |
|---|---|---|---|
| ៣៣. លោកជំទាវ **ម៉ៅ ធីតា** | | អនុរដ្ឋលេខាធិការ | សមាជិកា |
| ៣៤. ឯកឧត្តម | **សេង សក្កដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ | សមាជិក |
| ៣៥. ឯកឧត្តម | **ហ៊ាំង តុលា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៣៦. ឯកឧត្តម | **ហ៊ីង ស៊ីដេត** | អគ្គនាយក អ.ប.វ. | សមាជិក |
| ៣៧. ឯកឧត្តម | **ហៃ ហ៊ុនឡេង** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |

**ប្រការ២ ._**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- រៀបចំយន្តការដោះស្រាយករណីរោងចក្រ សហគ្រាសបិទទ្វារ ឬព្យួរកិច្ចសន្យាដោយសារការរីករាលដាលជំងឺកូវីដ-១៩ ស្របតាមវិធានការរបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការងារ
- រៀបចំយន្តការដោះស្រាយករណីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩
- ពិនិត្យសម្រេចលើរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល
- សហការ និងសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ជំរុញការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព។

**ប្រការ៣ ._**

គណៈកម្មការនេះ មានអនុគណៈកម្មការចំនួន៥ និងលេខាធិការដ្ឋានមួយ ជាជំនួយការ ដូចខាងក្រោម៖

**ក-អនុគណៈកម្មការចាក់វ៉ាក់សាំងជូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ** មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ហេង សួរ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម | **ឡៅ ហ៊ីម** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ម៉ុង គីមហេង** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. | ឯកឧត្តម | **ម៉ន ត្រីយ៉ា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥. | លោកជំទាវ | **សុវណ្ណ វណ្ណារតន៍** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦. | ឯកឧត្តម | **ឡេង សៃ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧. | ឯកឧត្តម | **ឱុយ ស៊ីផាន់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៨. | ឯកឧត្តម | **ឱុយ រិទ្ធ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៩. | លោកជំទាវ | **សូស រដ្ឋាធី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ១០. | លោកជំទាវ | **ជា សុខនី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ១១. | ឯកឧត្តម | **សោម ចំណាន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ១២. | ឯកឧត្តម | **ចឡេ សំអេង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ១៣. | លោកជំទាវ | **ម៉ៅ ធីតា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ១៤. | ឯកឧត្តម | **សេង សក្កដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ | សមាជិក |
| ១៥. | ឯកឧត្តម | **ហ៊ាំង តុលា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

| | | | |
|---|---|---|---|
| ១៦. ឯកឧត្តម | **អ៊ុក ចាន់ធូ** | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៧. ឯកឧត្តម | **ឡេង តុង** | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៨. ឯកឧត្តម | **គង់ ធារ័ត្ន** | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៩. លោក | **គឹម កែវចរស្មី** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សហការជាមួយគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីសម្របសម្រួលការចាក់វ៉ាក់សាំងជូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ
- រៀបចំផែនការ ពិនិត្យវាយតម្លៃកម្រិតហានិភ័យ និងកំណត់អាទិភាពភូមិសាស្ត្ររាជធានី ខេត្ត ទីតាំងរោងចក្រ សហគ្រាស និងមុខសញ្ញាកម្មករនិយោជិត ដែលត្រូវចាក់វ៉ាក់សាំង
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ បំពាក់បំប៉ន និងហ្វឹកហាត់បន្ថែមដល់ពេទ្យការងារ ដើម្បីចូលរួមការងារចាក់វ៉ាក់សាំងជូនកម្មករនិយោជិត
- ប្រមូលចងក្រងគ្រប់គ្រងស្ថិតិ និងទិន្នន័យអ្នកដែលត្រូវចាក់វ៉ាក់សាំងតាមគោលដៅ និងមុខសញ្ញានីមួយៗ
- សហការជាមួយភាគីពាក់ព័ន្ធរៀបចំសេចក្តីជូនដំណឹងស្តីពី នីតិវិធីនៃការចុះឈ្មោះលក្ខខណ្ឌសុខភាព និងឯកសារ ដែលត្រូវភ្ជាប់មកជាមួយនៅពេលចាក់វ៉ាក់សាំង ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប័ណ្ណសម្គាល់ ឬលិខិតបញ្ជាក់អត្តសញ្ញាណជាបុគ្គលិកនៅតាមរោងចក្រ សហគ្រាស ដែលត្រូវចាក់វ៉ាក់សាំង
- រៀបចំសេចក្តីជូនដំណឹងស្តីពីកាលវិភាគ ម៉ោង និងកម្មវិធីចាក់វ៉ាក់សាំងនៅតាមទីតាំងនីមួយៗ
- រៀបចំលំហូរ និងយន្តការនៃដំណើរការចាក់វ៉ាក់សាំងនៅតាមទីតាំងនីមួយៗ
- រៀបចំកំណត់ និងបែងចែកតួនាទីភារកិច្ចមន្ត្រី ដែលបំពេញការងារនៅតាមទីតាំងត្រូវចាក់វ៉ាក់សាំង
- សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងថែរក្សាវ៉ាក់សាំងនៅក្នុងអំឡុងពេលចាក់
- សម្របសម្រួលជាមួយនិយោជក ដើម្បីផ្តល់ទីតាំង និងផ្តល់ការគាំទ្រនានាពេលចាក់វ៉ាក់សាំង
- សហការជាមួយអាជ្ញាធរដែនដី និងរដ្ឋបាលរោងចក្រ សហគ្រាស ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ គម្លាតសង្គម និងការពារសន្តិសុខនៅតាមបណ្តាទីតាំងចាក់វ៉ាក់សាំងនីមួយៗ
- រៀបចំទិញ ឬស្នើសុំ និងគ្រប់គ្រងឧបករណ៍ សម្ភារ បរិក្ខារ និងគ្រឿងឧបភោគ បរិភោគនៅតាមទីតាំងដែលត្រូវចាក់វ៉ាក់សាំង
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**ខ-អនុគណៈកម្មការដោះស្រាយករណីរោងចក្រ សហគ្រាស ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ហុង ជឿន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម | **ទេស រុក្ខាផល** | អគ្គលេខាធិការ អ.គ.ក.ប | អនុប្រធាន |
| ៣. ឯកឧត្តម | **ហាន្យ ហោម** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៤. ឯកឧត្តម | **ចន្យ សុវណ្ណា** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៥. លោកជំទាវ | **ឃ្លោក ម៉េងឌុល** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិកា |
| ៦. ឯកឧត្តម | **ហែម ហឿន** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |

| | | | | |
|---|---|---|---|---|
| ៧. | ឯកឧត្តម | **និន ចណ្ណៈ** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៨. | ឯកឧត្តម | **អ៊ូ រតនា** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៩. | ឯកឧត្តម | **ខៀវ សាធុច** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ១០. | ឯកឧត្តម | **ហ៊ីច រស្មី** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ១១. | ឯកឧត្តម | **ម៉ុល ចិបុល** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ១២. | មន្ត្រីរាជការនៃ អ.គ.ក.ប | | | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទំនាក់ទំនងជាមួយរដ្ឋបាល ឬតំណាងរោងចក្រ សហគ្រាស ដើម្បីសហការកំណត់ទីតាំងបំពេញការងាររបស់កម្មករនិយោជិត ឬនិយោជកដែលមានករណីសង្ស័យ ឬវិជ្ជមានកូវីដ-១៩ និងកំណត់អត្តសញ្ញាណអ្នកដែលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល
- រៀបចំបញ្ជីឈ្មោះកម្មករនិយោជិត ឬនិយោជក ដែលជាប់សង្ស័យប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ផ្តល់ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីទាក់ទងទៅក្រុមឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល ចុះពិនិត្យវាយតម្លៃយកសំណាក និងកំណត់ចំណាត់ថ្នាក់ហានិភ័យកម្មករនិយោជិត ឬនិយោជក ដែលជាប់សង្ស័យ និងផ្តល់ជូនអាជ្ញាធរមូលដ្ឋានដែលកម្មករនិយោជិត ឬនិយោជកកំពុងស្នាក់នៅបច្ចុប្បន្ន
- សហការជាមួយរដ្ឋបាល ឬតំណាងរោងចក្រ សហគ្រាស ក្នុងការចាត់ចែងបញ្ជូនកម្មករនិយោជិត ឬនិយោជក ដែលបានយកសំណាកនិងកំណត់ហានិភ័យរួចហើយ ទៅធ្វើចត្តាឡីស័កនៅតាមមណ្ឌល ឬនៅតាមរោងចក្រ សហគ្រាស
- ផ្តល់បញ្ជីឈ្មោះជូនរដ្ឋបាលរាជធានី ខេត្ត ចំពោះកម្មករនិយោជិត ឬនិយោជក ដែលត្រូវបានកំណត់ឱ្យធ្វើចត្តាឡីស័កនៅតាមផ្ទះ
- សម្របសម្រួលជាមួយរដ្ឋបាល ឬតំណាងរោងចក្រ សហគ្រាស ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើចត្តាឡីស័ក តាមដាន និងរាយការណ៍ពីស្ថានភាពសុខភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតទាំងនោះ។
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្នុងការកំណត់ឱ្យបើកដំណើរការឡើងវិញចំពោះរោងចក្រ សហគ្រាស ដែលត្រូវផ្អាកដំណើរការបណ្តោះអាសន្នដោយជំងឺកូវីដ-១៩
- ដោះស្រាយវិវាទការងារ កូដកម្ម ឬបាតុកម្មដែលអាចកើតមានឡើង ដោយសារផលប៉ះពាល់ពីករណីជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**គ-អនុគណៈកម្មការដោះស្រាយករណីថែទាំសុខភាព** មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **អ៊ិត សមហិញ្ញា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក បេឡាជាតិសន្តិសុខសង្គម | ប្រធាន |
| ២. | ឯកឧត្តម | **ស៊ុំ សោភ័ណ** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង ប.ស.ស. | អនុប្រធាន |
| ៣. | ឯកឧត្តម | **ម៉ែន នរៈឫទ្ធ** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង ប.ស.ស. | អនុប្រធាន |
| ៤. | ឯកឧត្តម | **សូន ស៊ីឡៀខ** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង ប.ស.ស. | អនុប្រធាន |
| ៥. | ឯកឧត្តម | **ម៉េខ ហុខ** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង ប.ស.ស. | អនុប្រធាន |
| ៦. | ឯកឧត្តម | **អេត បុរ៉ាត់** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង ប.ស.ស. | អនុប្រធាន |
| ៧. | ឯកឧត្តម | **ឃី គន្ធិដ្ឋា** | ទីប្រឹក្សាអមក្រសួង និង ជាអនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៨. | លោក | **កែវ មីនណា** | ប្រធាននាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម | សមាជិក |

| | | | | |
|---|---|---|---|---|
| ៩. | លោកស្រី | **សុខ សុលីណា** | ប្រធានន.រដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស | សមាជិកា |
| ១០. | លោកស្រី | **ម៉េត សុគន្ធឡាលីន** | ប្រធានន.គ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ | សមាជិកា |
| ១១. | លោក | **ជី សុរ** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| ១២. | លោក | **ឈៀង ពន្លក** | ប្រធាននាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម | សមាជិក |
| ១៣. | លោក | **ហេង សុផាន់ណារិទ្ធ** | ប្រធានន. សេវាអតិថិជន និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៤. | លោក | **ហុង សុខហៀម** | ប្រធាននាយកដ្ឋានបញ្ជិកា និងភាគទាន | សមាជិក |
| ១៥. | លោក | **សុក បូរ៉ា** | ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម | សមាជិក |
| ១៦. | លោក | **ឆត ម៉ុឡារី** | ប្រធាននាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល | សមាជិក |
| ១៧. | លោក | **គាត ពុធណារិទ្ធិ** | ប្រធានន.គ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម | សមាជិក |
| ១៨. | លោក | **ជៀក លីម៉េង** | ប្រធាននាយកដ្ឋានស្តារនីតិសម្បទា | សមាជិក |
| ១៩. | មន្ត្រីរាជការនៃ ប.ស.ស. | | | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងរបបសន្តិសុខសង្គម
- រៀបចំយន្តការដោះស្រាយអត្ថប្រយោជន៍ផ្នែករបបសន្តិសុខសង្គម ចំពោះកម្មករនិយោជិតដែលរោងចក្រ សហគ្រាស បានបិទទ្វារ ឬព្យួរកិច្ចសន្យាការងារដោយសារការរីករាលដាលជំងឺកូវីដ-១៩
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**ឃ-អនុគណៈកម្មការច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត** មានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | លោកជំទាវ | **សុវណ្ណ វណ្ណារតន៍** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម | **អ៊ិន ខេមរា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម | **កុយ ទេពដារាវុធ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. | ឯកឧត្តម | **សោម ចំណាន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៥. | ឯកឧត្តម | **លឹម ស៊ីយហុង** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងការងារ | អនុប្រធាន |
| ៦. | ឯកឧត្តម | **អ៊ឹក ចាន់ធូ** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ៧. | ឯកឧត្តម | **ឡេង តុង** | ទីប្រឹក្សាអមក្រសួង និងជាប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៨. | លោក | **ហ្វូន សឿ** | អគ្គនាយករងការងារ | សមាជិក |
| ៩. | លោក | **ហ្វូន សុខភានាថ** | អគ្គនាយករងការងារ | សមាជិក |
| ១០. | លោក | **ខេង សំបូរ** | អគ្គលេខាធិការរង | សមាជិក |
| ១១. | លោកស្រី | **សែន ទេវចន្ទនិតា** | ទីប្រឹក្សាអមក្រសួង | សមាជិកា |
| ១២. | លោក | **តាំង សំណាង** | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ១៣. | លោក | **ប្រ៊ុន ថេរ៉ាវង្ស** | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៤. | លោក | **ទ៉ែត វណ្ណារិទ្ធ** | នាយកវិទ្យាស្ថានជាតិការងារ | សមាជិក |
| ១៥. | លោក | **ម៉ាញ ណារិទ្ធ** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៦. | លោក | **តុន សុភ័ក្ត** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាននាយកដ្ឋានសហប្រតិបត្តការអន្តរជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ១៧. លោក | **សំង សេងលី** | ទីប្រឹក្សាអមក្រសួង និងជាអនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៨. លោក | **ខេម ម៉ិនឈាន** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៩. លោក | **ឌីម ឧត្តម** | ប្រធានការិយាល័យនៃន.អធិការកិច្ចការងារ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- តាមដាន និងសិក្សាស្រាវជ្រាវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- ចូលរួមផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- ផ្សព្វផ្សាយរាល់លិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងសេចក្តីជូនដំណឹងដែលពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- បកស្រាយបទប្បញ្ញត្តិច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ ការផ្អាកសកម្មភាពអាជីវកម្ម ឬការបិទរោងចក្រ សហគ្រាស ដោយសារការអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលដាក់ចេញដោយរាជរដ្ឋាភិបាល
- បកស្រាយរាល់ចម្ងល់និងសំណួរពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងសេចក្តីណែនាំក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ និងកាតព្វកិច្ចរបស់រោងចក្រ សហគ្រាស និងកម្មករនិយោជិត
- រៀបចំសេចក្តីណែនាំនិងសេចក្តីជូនដំណឹងអំពីការអនុវត្តវិធានការសុខាភិបាល និងការពង្រឹងវិធានការសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- រៀបចំសេចក្តីណែនាំ និងសេចក្តីជូនដំណឹងអំពីការអនុវត្តវិធានការធ្វើចត្តាឡីស័ករបស់កម្មករនិយោជិតស្របតាមវិធានការសុខាភិបាល និងការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស ដោយសារការអនុវត្តវិធានការចត្តាឡីស័ក ឬករណីវិជ្ជមានជំងឺកូវីដ-១៩
- ដោះស្រាយបញ្ហាផ្សេងៗ ក្នុងទំនាក់ទំនងវិជ្ជាជីវៈ ដែលកើតចេញពីការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩
- បកស្រាយបទប្បញ្ញត្តិច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ ការផ្អាក និងការបិទរោងចក្រសហគ្រាស ដែលកើតចេញពីការរីករាលដាលជំងឺកូវីដ-១៩
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**ង-អនុគណៈកម្មការដោះស្រាយករណីគ្រោះស្គាលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ពេជ សោភ័ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. ឯកឧត្តម | **ប៉ុក ប៉ាន់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម | **គុយ រតនា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម | **ឡៅ ហ៊ីម** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥. ឯកឧត្តម | **ប៉ាន់ ណូរ៉ា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៦. | ឯកឧត្តម | **ហ៊ីង ស៊ីដេត** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |
| ៧. | លោកជំទាវ | **ឱុង សុភាព** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង អ.ប.វ | សមាជិកា |
| ៨. | ឯកឧត្តម | **ថង សាម៉ុន** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង អ.ប.វ | សមាជិក |
| ៩. | ឯកឧត្តម | **តាន់ សម្បត្តិ** | ទីប្រឹក្សាអមក្រសួង និងជា<br>ប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | សមាជិក |
| ១០. | លោក | **អាន ថៃសុជាតិ** | អគ្គនាយករង អ.ប.វ | សមាជិក |
| ១១. | លោក | **គួង ចិសិទ្ធ** | អគ្គនាយករង អ.ប.វ | សមាជិក |
| ១២. | លោកស្រី | **ឃឹម ពេជ្រម៉ាលីកា** | អគ្គនាយករង អ.ប.វ | សមាជិកា |
| ១៣. | លោក | **ឆាយ សុភា** | អគ្គនាយករង អ.ប.វ | សមាជិក |
| ១៤. | លោកស្រី | **សៅ សុគន្ធអេក្សា** | ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិកា |
| ១៥. | លោកស្រី | **ឃុន លក្ខិណា** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិកា |
| ១៦. | លោក | **ឆាង សាក់** | ប្រធាននាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា | សមាជិក |
| ១៧. | លោក | **សាន សេង** | ប្រធាននាយកដ្ឋានធានាគុណភាព | សមាជិក |
| ១៨. | លោកស្រី | **ឧង អណ្ណិកា** | ប្រធាននាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ | សមាជិកា |
| ១៩. | មន្ត្រីរាជការនៃ អ.ប.វ | | | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដល់កម្មករនិយោជិតដែលរងផលប៉ះពាល់ដោយសារការរីករាលដាលជំងឺកូវីដ-១៩
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**ច.លេខាធិការដ្ឋាន** ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ហេង សួរ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម | **ហុង ជឿន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ខុយ រិទ្ធ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. | ឯកឧត្តម | **សេង សក្តា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា<br>អគ្គនាយកការងារ | អនុប្រធាន |
| ៥. | ឯកឧត្តម | **ហាំង តុលា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦. | ឯកឧត្តម | **ហ៊ីង ស៊ីដេត** | អគ្គនាយក អ.ប.វ. | អនុប្រធាន |
| ៧. | ឯកឧត្តម | **គួច សុមាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន<br>ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា | អនុប្រធាន |
| ៨. | ឯកឧត្តម | **ម៉េង ហុង** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងប.ស.ស. | សមាជិក |
| ៩. | ឯកឧត្តម | **សេង សុសាន** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង រ.ហ. | សមាជិក |
| ១០. | ឯកឧត្តម | **ឆាង ស៊ីងឆេង** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករងការងារ | សមាជិក |
| ១១. | ឯកឧត្តម | **ថង សាម៉ុន** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង អ.ប.វ. | សមាជិក |
| ១២. | ឯកឧត្តម | **ម៉ុល ចិបុល** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ១៣. | ឯកឧត្តម | **អ៊ិត ចាន់ធូ** | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |

| | | | | |
|---|---|---|---|---|
| ១៤. | ឯកឧត្តម | ឡេង តុង | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៥. | ឯកឧត្តម | គង់ ឆារ៉ែត | ទីប្រឹក្សាអមក្រសួង និង<br>ជាប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៦. | ឯកឧត្តម | ឃី ភក្តិដ្ឋា | ទីប្រឹក្សាអមក្រសួង និង<br>ជាអនុប្រធាននាយកដ្ឋានពេទ្យការងារ | សមាជិក |
| ១៧. | លោកស្រី | ម៉ុត ករុណា | អគ្គលេខាធិការរង អ.គ.ជ.ព. | សមាជិកា |
| ១៨. | លោក | តាំង ផេងរិទ្ធី | អគ្គនាយករងការងារ | សមាជិក |
| ១៩. | លោក | ជ្រុន ចេរ៉ាចន្ទ | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ២០. | លោក | គឹម កែវរស្មី | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ២១. | លោក | ម៉ែត ចណ្ណារិទ្ធ | នាយកវិទ្យាស្ថានជាតិការងារ | សមាជិក |
| ២២. | លោក | ខេម ម៉ិនឈាន | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ២៣. | លោកស្រី | ជា សោភា | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិកា |
| ២៤. | លោក | ឃឹម សុសំរេច | ប្រធានការិយាល័យ | សមាជិក |
| ២៥. | លោក | ខួន សទ្ធី | ជំនួយការឯកឧត្តមរដ្ឋលេខាធិការ | សមាជិក |

លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំតាមដានវឌ្ឍនភាពការងាររបស់គណៈកម្មការ និងអនុគណៈកម្មការ
- រៀបចំរបាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំនានារបស់គណៈកម្មការ
- ព្រាងរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ឯកឧត្តមប្រធានគណៈកម្មការ។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២១

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មការជាតិ គ.ប.ខ.
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  «ដើម្បីជូនជ្រាប»
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  «ដើម្បីអនុវត្ត»
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ